

# អាវភ្លៀវពណ៌ក្រហម

Kiran Kasturia

Zainab Tambawalla

letsreadasia.org



ថ្ងៃអាទិត្យ ប៉ាម៉ាក់របស់ ម៉ានូ បាន
ទិញអាវភ្លៀងពណ៌ក្រហមមួយ
ឲ្យ ម៉ានូ។ «ម៉ាក់! តើខ្ញុំអាចពាក់វា
ឥឡូវនេះបានទេ?» ម៉ានូ សួរម្ដាយ។
«មិនបានទេកូន ពេលនេះមេឃស្រឡះ
អត់មានភ្លៀងទេ» ម្ដាយតប។



ថ្ងៃចន្ទ មេឃបើកថ្ងៃស្រឡះល្អណាស់។ «ម៉ាក់! ថ្ងៃនេះនឹងមានភ្លៀងឬអត់?» ម៉ានូ សួរ។ «ថ្ងៃនេះអត់មានភ្លៀងទេ ម៉ានូ។ បើកូនពាក់អាវភ្លៀង កូននឹងចម្លែកខុសពីគេហើយ» ម្ដាយ ម៉ានូ និយាយ។



ថ្ងៃអង្គារ មេឃមានពណ៌ខៀវ។
«ម៉ាក់!តើពេលណាបំណងកូនក្លាយជា
ការពិត?» ម៉ានូ សួរ។ «មិនមែនថ្ងៃនេះ
ទេកូន មានតែពពកសម្លួយដុំនៅ
លើមេឃហ្នឹង!» ម្ដាយឆ្លើយ។



ថ្ងៃពុធ មេឃក្ដៅណាស់។ «ម៉ាក់! ហេតុអ្វីបានជាមេឃអត់ភ្លៀង?» ម៉ានូ សួរ។ «កូនប្រុស! ម៉ាក់គិតថាមេឃ នឹងភ្លៀងឆាប់ៗនេះ។ ប្រហែលជាមុន ពេលថ្ងៃត្រង់នេះ» ម្ដាយតប។



ថ្ងៃព្រហស្បតិ៍ ម៉ានូ បានទៅដើរលេង។ «ម៉ាក់! បើមានភ្លៀងធ្វើម៉េចទៅ? តើកូនអាចយកអាវភ្លៀងទៅជាមួយបានទេ?» ម៉ានូ សួរ។ «ទេកូន! មេឃមានពពកពណ៌សនៅខ្ពស់ណាស់ ថ្ងៃនេះមេឃមិនភ្លៀងទេ» ម្ដាយនិយាយ។



ថ្ងៃសុក្រ មេឃមានពពកច្រើន។ «ម៉ាក់! តើថ្ងៃនេះនឹងមានភ្លៀងដែរទេ?» ម៉ានូ សួរម្តាយឮៗ។ «មេឃប្រហែលជាភ្លៀង ព្រោះមានពពកខ្មៅនៅទាបបែបនេះ» ម្តាយប្រាប់កូន។



ថ្ងៃសៅរ៍ មានសំឡេងផ្គរលាន់។ គ្រឹមៗ!
«ម៉ាក់! វាជាសំឡេងផ្គរលាន់មែនទេ?
វានឹងមានភ្លៀងធ្លាប់ៗនេះមែនទេ?”
ម៉ានូ សួរម្តាយ។



ទីបំផុត មេឃក៏ចាប់ផ្ដើមភ្លៀង។
«អូហ៍! មេឃភ្លៀងហើយ មេឃ
ភ្លៀងហើយ» ម៉ានូ ច្រៀងហើយ
រត់ចេញទៅខាងក្រៅ។



«ម៉ានូ!» ម្ដាយស្រែកហៅនិងរត់តាម
ម៉ានូ «កូនភ្លេចអាវភ្លៀងរបស់កូន
ហើយ!»

Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org

To read more books like this and get further information about this book, visit letsreadasia.org

Original Story
The Red Raincoat, author: Kiran Kasturia . illustrator: by Zainab Tambawalla. Published by Pratham Books, https://storyweaver.org.in/stories/369-the-red-raincoat © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/

Contributing translators: Somey Chheang and Sivngim Nguon